# ពិធីការបើកឡើងវិញសម្រាប់កន្លែងបោះជំរុំ ឧទ្យាន RV និងបន្ទប់កាប៊ីនសម្រាប់ជួលៈ ឧបសម្ព័ន្ធ O

មានប្រសិទ្ធភាពចាប់ពីថ្ងៃសុក្រទី 12 ខែមិថុនា ឆ្នាំ 2020

**បច្ចុប្បន្នភាពថ្មីៗ (ការផ្លាស់ប្តូរត្រូវបានរំលេចដោយពណ៌លឿង)**

**12/18/20៖** បានធ្វើបច្ចុប្បន្នភាពដើម្បីអនុញ្ញាតឲ្យសួនកម្សាន្តបើកដំណើរការដោយអនុលោមតាមការណែនាំរបស់រដ្ឋ។

**12/06/20៖** ដោយអនុលោមតាមសេចក្តីបង្គាប់ឲ្យស្ថិតនៅផ្ទះថ្នាក់តំបន់របស់រដ្ឋ កន្លែងបោះជំរុំ ឧទ្យាន RV និងបន្ទប់កាប៊ីនសម្រាប់ជួល មិនត្រូវអនុញ្ញាតឲ្យមានការស្នាក់នៅពេលយប់ឡើយ ដែលមានប្រសិទ្ធភាពចាប់ពីថ្ងៃទី 6 ខែធ្នូ ឆ្នាំ 2020 វេលាម៉ោង 11:59 អធ្រាត្រ (PST) រហូតដល់មានការជូនដំណឹងជាថ្មី។

**12/2/20៖**

- បុគ្គលិកដែលធ្វើការនៅក្នុងបន្ទប់តូច ដោយរាប់បញ្ចូលទាំងបន្ទប់តូចដែលមានរបាំងខណ្ឌចែក ត្រូវតែពាក់របាំងមុខ។ អាងហែលទឹកខាងក្រៅអគារ អាចបើកដំណើរការសម្រាប់តែការហែលជាជំដែលមានការកំណត់ត្រឹមត្រូវប៉ុណ្ណោះ (អ្នកហែលទឹកម្នាក់ក្នុងមួយផ្លូវ)។ ទាំងនេះគឺជាវិធានការណ៍បណ្តោះអាសន្នដោយអនុលោមតាមសេចក្តីបង្គាប់របស់មន្ត្រីសុខាភិបាលបណ្តោះអាសន្ន ដែលបានចេញនៅថ្ងៃទី 28 ខែវិច្ឆិកា ឆ្នាំ 2020។ សេចក្តីបង្គាប់នេះមានប្រសិទ្ធភាពរហូតដល់មានការជូនដំណឹងជាថ្មី។
- នៅគ្រប់ពេលវេលាទាំងអស់នៅពេលបរិភោគ ឬផឹក បុគ្គលិកត្រូវតែរក្សាគំលាត 6 ហ្វីតពីអ្នកដទៃ និងគួរធ្វើដូច្នោះនៅខាងក្រៅអគារ បើសិនជាអាចធ្វើបាន។ ការបរិភោគឬការផឹកនៅក្នុងបន្ទប់តូច ឬស្ថានីយការងារ គឺប្រសើរជាងការបរិភោគនៅក្នុងបន្ទប់សម្រាក។

នាយកដ្ឋានសុខភាពសាធារណៈរបស់ខោនធី Los Angeles កំពុងអនុវត្តវិធីសាស្រ្តតាមដំណាក់កាល ដែលបានគាំទ្រដោយវិទ្យាសាស្រ្ត និងជំនាញការសុខភាពសាធារណៈ ដើម្បីអនុញ្ញាតឲ្យទីកន្លែងជាក់លាក់បើកទ្វារឡើងវិញដោយសុវត្ថិភាព។ សេចក្តីបង្គាប់ខាងក្រោមគឺជាក់លាក់សម្រាប់កន្លែងបោះជំរុំ/ឧទ្យាន RV និងកាប៊ីនសម្រាប់ជួលដែលបានអនុញ្ញាតឲ្យបើកទ្វារដោយសេចក្តីបង្គាប់ពីមន្ត្រីសុខាភិបាលសាធារណៈរដ្ឋ។ បន្ថែមលើលក្ខខណ្ឌដែលបានដាក់ចុះដោយអភិបាលរដ្ឋទៅលើទីកន្លែងជាក់លាក់ទាំងនេះ អាជីវកម្មប្រភេទទាំងនេះក៏ត្រូវគោរពតាមលក្ខខ័ណ្ឌដែលបានចែងនៅក្នុងបញ្ជីត្រួតពិនិត្យនេះផងដែរ។

ដោយអនុលោមតាមសេចក្តីបង្គាប់ឲ្យស្ថិតនៅផ្ទះថ្នាក់តំបន់របស់រដ្ឋចេញនៅថ្ងៃទី 3 ខែធ្នូ ឆ្នាំ 2020 និងមានប្រសិទ្ធភាពចាប់ពីថ្ងៃទី 6 ខែធ្នូ ឆ្នាំ 2020 វេលាម៉ោង 11:59 អធ្រាត្រ (PST) រហូតដល់មានការជូនដំណឹងជាថ្មី កន្លែងបោះជំរុំ ឧទ្យាន RV និងបន្ទប់កាប៊ីនសម្រាប់ជួល មិនត្រូវអនុញ្ញាតឲ្យមានការស្នាក់នៅពេលយប់ឡើយ។

សូមកត់សម្គាល់៖ ឯកសារនេះអាចនឹងត្រូវបានធ្វើបច្ចុប្បន្នភាព នៅពេលដែលមានព័ត៍មាន និងធនធានបន្ថែម ដូច្នេះសូមប្រាកដថាបានពិនិត្យមើលគេហទំព័រ LA County http://www.ph.lacounty.gov/media/Coronavirus/ ជាប្រចាំសម្រាប់បច្ចុប្បន្ន 0ភាពផ្សេងៗទៅលើឯកសារនេះ និងការណែនាំដែលទាក់ទង។

បញ្ជីត្រួតពិនិត្យនេះគ្របដណ្តប់៖

(1) គោលការណ៍ និងការអនុវត្តនៅកន្លែងធ្វើការដើម្បីការពារសុខភាពបុគ្គលិក

(2) វិធានការណ៍ដើម្បីធានាបាននូវការរក្សាគំលាតរាងកាយ

(3) វិធានការណ៍ដើម្បីធានាបាននូវការគ្រប់គ្រងការឆ្លងជំងឺ

(4) ការទំនាក់ទំនងជាមួយបុគ្គលិក និងសាធារណៈជន

(5) វិធានការណ៍ដើម្បីធានាបាននូវការប្រើប្រាស់សេវាកម្មសំខាន់ៗដោយស្មើភាព

ចំណុចសំខាន់ៗទាំងប្រាំនេះ ត្រូវតែបានដោះស្រាយនៅពេលទីកន្លែងរបស់អ្នកបង្កើតពិធីការបើកឡើងវិញណាមួយ។

**កន្លែងបោះជំរុំ ឧទ្យាន RV និងកាប៊ីនសម្រាប់ជួលទាំងអស់ដែលត្រូវបានគ្របដណ្តប់ដោយការណែនាំនេះ ត្រូវតែដាក់ចុះនូវវិធានាការដែលអាចអនុវត្តបានទាំងអស់ ដែលមានរាយនៅខាងក្រោម និងត្រូវត្រៀមខ្លួនដើម្បីពន្យល់ពីមូលហេតុនៃវិធានការណ៍ណាមួយដែលមិនត្រូវបានអនុវត្ត គឺមិនអាចអនុវត្តបាន។**

ឈ្មោះទីកន្លែង៖

អាសយដ្ឋានទីកន្លែង៖

## A. គោលការណ៍ និងការអនុវត្តនៅកន្លែងធ្វើការដើម្បីការពារសុខភាពបុគ្គលិក (គូសធីកទាំងអស់ដែលអនុវត្តសម្រាប់ទីកន្លែង)

- ❑ មនុស្សគ្រប់គ្នាដែលអាចបំពេញកិច្ចការរបស់ខ្លួនពីផ្ទះ ត្រូវបានណែនាំឲ្យធ្វើដូច្នោះ។
- ❑ បុគ្គលិកងាយរងគ្រោះ (អ្នកដែលមានអាយុលើស 65 ឆ្នាំ ឬអ្នកដែលមានបញ្ហាសុខភាពរ៉ាំរ៉ៃ) ត្រូវបានកំណត់ ឲ្យធ្វើការងារដែលអាចធ្វើបានពីផ្ទះនៅគ្រប់ពេលដែលអាចធ្វើទៅបាន។
- ❑ ដំណើរការការងារត្រូវបានកែទម្រង់ឡើងវិញទៅតាមកម្រិតដែលអាចធ្វើបាន ដើម្បីបង្កើនឱកាសសម្រាប់ឲ្យបុគ្គលិកធ្វើការងារពីផ្ទះ។ ពិចារណាផ្តល់ឲ្យបុគ្គលិកដែលស្នើសុំកែប្រែភារកិច្ច ដែលកាត់បន្ថយការប៉ះពាល់របស់ពួកគេជាមួយភ្ញៀវ និង បុគ្គលិកផ្សេងទៀត។
- ❑ កាលវិភាគឆ្លាស់វេនគ្នា ឬប្តូរវេនគ្នាត្រូវបានអនុវត្តដើម្បីបង្កើនការរក្សាគំលាតរាងកាយជាអតិបរមា។
- ❑ បុគ្គលិកទាំងអស់ (រាប់បញ្ចូលទាំងបុគ្គលិកទទួលប្រាក់ឈ្នួល និងអ្នកស្ម័គ្រចិត្ត ត្រូវបានសំដៅជារួមថា "បុគ្គលិក") ត្រូវបានប្រាប់ថាកុំមកធ្វើការបើសិនជាឈឺ ឬបើសិនជាពួកគេបានប៉ះពាល់ជាមួយមនុស្សដែលមានជំងឺ COVID-19។ បុគ្គលិកយល់និងអនុវត្តតាមការណែនាំរបស់ DPH សម្រាប់ការដាក់ខ្លួនឲ្យនៅដាច់ដោយឡែក និងការនៅដាច់ពីគេ បើសិនជាអាចអនុវត្តបាន។ គោលការណ៍សុំច្បាប់ឈប់សម្រាកនៅកន្លែងធ្វើការ ត្រូវបានពិនិត្យឡើងវិញ និងបានកែប្រែដើម្បីធានាថាបុគ្គលិកមិនត្រូវបានពិន័យនៅពេលពួកគេស្ថិតនៅផ្ទះដោយសារជំងឺ។
  - o សូមមើលព័ត៌មានបន្ថែមស្តីពី កម្មវិធី រដ្ឋាភិបាលដែលគាំទ្រការឈប់សម្រាកឈឺនិងសំណងបុគ្គលិកសម្រាប់ជំងឺ COVID-19 ដោយរាប់បញ្ចូលទាំងសិទ្ធិសុំច្បាប់ឈប់សម្រាកឈឺរបស់បុគ្គលិកក្រោម ច្បាប់ស្តីពីការឆ្លើយតបនឹងមេរោគក្លូរ៉ូណាដោយយកគ្រួសារជាអាទិភាព (Families First Coronavirus Response Act) និងសិទ្ធិរបស់បុគ្គលិកដើម្បីទទួលអត្ថប្រយោជន៍សំណងបុគ្គលិក និងការសន្និដ្ឋានភាពទាក់ទងនឹងការងារនៃការប៉ះពាល់ជាមួយជំងឺ COVID-19 ដែលកើតឡើងចន្លោះថ្ងៃទី 19 ខែមីនា និងថ្ងៃទី 5 ខែកក្កដាដោយអនុលោមតាមបទបញ្ជាប្រតិបត្តិលេខ N-62-20 របស់អភិបាលរដ្ឋ។
- ❑ បន្ទាប់ពីទទួលព័ត៌មានថាមានបុគ្គលិកម្នាក់ ឬច្រើននាក់ធ្វើតេស្តវិជ្ជមាន ឬមានរោគសញ្ញាដែលដូចគ្នាជាមួយជំងឺ COVID-19 (ករណី) និយោជកមានគម្រោង ឬពិធីការដើម្បីឲ្យករណីទាំងនោះដាក់ខ្លួនឲ្យនៅដាច់ដោយឡែកនៅផ្ទះ និងតម្រូវឲ្យដាក់ខ្លួនឲ្យនៅដាច់ពីគេភ្លាមៗសម្រាប់បុគ្គលិកដែលមានការប៉ះពាល់ជាមួយករណីនៅកន្លែងធ្វើការ។ គម្រោងរបស់និយោជកគួរតែពិចារណាពីពិធីការសម្រាប់បុគ្គលិកដែលបាននៅដាច់ពីគេទាំងអស់ ដើម្បីអាចទទួលបាន ឬធ្វើតេស្តរកជំងឺ COVID-19 ដើម្បីកំណត់ថាតើមានការប៉ះពាល់នៅកន្លែងធ្វើការបន្ថែមទៀតឬទេ ដែលអាចតម្រូវឲ្យមានវិធានការណ៍គ្រប់គ្រងជំងឺ COVID-19 បន្ថែម។ សូមមើលការណែនាំសុខភាពសាធារណៈស្តីពី ការឆ្លើយតបនឹងជំងឺ COVID-19 នៅកន្លែងធ្វើការ។
- ❑ ការត្រួតពិនិត្យបុគ្គលិក ត្រូវបានធ្វើឡើងមុនពេលបុគ្គលិកអាចចូលក្នុងកន្លែងធ្វើការ។ ការពិនិត្យត្រូវតែរាប់បញ្ចូលការពិនិត្យពាក់ព័ន្ធនឹងការក្អក ការដកដង្ហើមខ្លី ការពិបាកដកដង្ហើម និងគ្រុនក្តៅឬគ្រុនរងា និងថាតើបុគ្គលនោះកំពុងស្ថិតក្រោមសេចក្តីបង្គាប់ឲ្យនៅដាច់ដោយឡែក ឬឲ្យនៅដាច់ពីគេនាពេលបច្ចុប្បន្នឬទេ។ ការពិនិត្យទាំងនេះអាចត្រូវបានធ្វើឡើងពីចម្ងាយ ឬដោយផ្ទាល់បន្ទាប់ពីបុគ្គលិកមកដល់។ ការពិនិត្យសីតុណ្ហភាពក៏គួរតែធ្វើឡើងនៅ កន្លែងធ្វើការផងដែរ បើសិនជាអាចធ្វើបាន។
- ❑ នៅក្នុងករណីដែលរកឃើញមាន 3 ករណីឬច្រើនជាងនេះនៅក្នុងទីកន្លែងក្នុងរយៈពេល 14 ថ្ងៃ នោះនិយោជកគួរ រាយការណ៍ពីចង្កោមនេះទៅនាយកដ្ឋានសុខភាពសាធារណៈតាមរយៈលេខ (888) 397-3993 ឬ (213) 240-7821។ បើសិនជាចង្កោមត្រូវបានរកឃើញនៅកន្លែងធ្វើការ នាយកដ្ឋានសុខភាពសាធារណៈ នឹងចាប់ផ្តើមការឆ្លើយតបចំពោះការឆ្លងជាចង្កោម ដែលរួមមានដូចជាការផ្តល់ការណែនាំ និងអនុសាសន៍អំពីការគ្រប់គ្រងការឆ្លងជំងឺ ជំនួយបច្ចេកទេស និងវិធានការណ៍គ្រប់គ្រងដែលជាក់លាក់សម្រាប់ទីកន្លែង។ អ្នកគ្រប់គ្រងករណីសុខភាពសាធារណៈ នឹងត្រូវបានចាត់តាំងដើម្បីធ្វើការស៊ើបអង្កេតការឆ្លងជាចង្កោមដើម្បីដឹកនាំការឆ្លើយតបនៅទីកន្លែង។
- ❑ បុគ្គលិកដែលមានការប៉ះពាល់ជាមួយអ្នកដទៃ ត្រូវបានទទួលរបាំងមុខសមស្រប ដែលគ្របច្រមុះ និងមាត់ ដោយឥតគិតថ្លៃ។ បុគ្គលិកត្រូវពាក់របាំងមុខគ្រប់ពេលវេលា ក្នុងអំឡុងថ្ងៃធ្វើការ នៅពេលប៉ះពាល់ ឬទំនងជា ប៉ះពាល់ជាមួយអ្នកដទៃ។ បុគ្គលិកដែលត្រូវបានណែនាំដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្ររបស់ខ្លួនថាពួកគេមិនគួរពាក់របាំងមុខ គួរពាក់សន្ទះបាំងមុខដែលមានក្រណាត់គ្របនៅគែមខាងក្រោម ដើម្បីអនុលោមតាមបទបញ្ជារបស់រដ្ឋ ដរាបណាលក្ខខ័ណ្ឌសុខភាពរបស់ពួកគេអនុញ្ញាត។ យកល្អគួរប្រើក្រណាត់គ្របដែលមានទម្រង់រឹតតឹងនៅខាងក្រោមចង្កា។ ម៉ាស់ដែលមានវ៉ាល់តែមួយផ្លូវគឺមិនគួរប្រើឡើយ។ បុគ្គលិក

មិនចាំបាច់ពាក់ក្រណាត់បាំងមុខពេលនៅម្នាក់ឯងនៅក្នុងការិយាល័យឯកជន ឬបន្ទប់តូចដែលមានរបាំងរឹងការពារខ្ពស់ជាងកម្ពស់បុគ្គលិកនៅពេលឈរនោះទេ។

- ❑ ដោយអនុលោមតាមសេចក្តីបង្គាប់របស់មន្ត្រីសុខាភិបាលដើម្បីគ្រប់គ្រងជំងឺ COVID-19៖ ការឆ្លើយតបនឹងការកើនឡើងខ្លាំងលំដាប់ថ្នាក់ទី 1 បានចេញនៅថ្ងៃទី 28 ខែវិច្ឆិកា ឆ្នាំ 2020 បុគ្គលិកទាំងអស់ត្រូវតែពាក់របាំងមុខគ្រប់ពេលវេលា លើកលែងតែពេលធ្វើការម្នាក់ឯងនៅក្នុងការិយាល័យឯកជនដោយបិទទ្វារជិត ឬនៅពេលបរិភោគ ឬផឹក។ ករណីលើកលែងដែលមានសម្រាប់បុគ្គលិកដែលធ្វើការនៅក្នុងបន្ទប់តូច ដោយមានរបាំងខ័ណ្ឌរឹងមាំហួសពីកម្ពស់របស់បុគ្គលិកពេលនេះត្រូវបានដកចោលដែលមានប្រសិទ្ធភាពក្នុងសេចក្តីបង្គាប់បណ្តោះអាសន្ននេះ ពោលគឺចាប់ពីម៉ោង 12:01 អធ្រាត្រ (PST) ថ្ងៃទី 30 ខែវិច្ឆិកា ឆ្នាំ 2020 រហូតដល់មានការជូនដំណឹងសារជាថ្មី។
- ❑ ដើម្បីប្រាកដថាម៉ាស់ត្រូវបានពាក់យ៉ាងខ្ជាប់ខ្ជួននិងត្រឹមត្រូវ បុគ្គលិកត្រូវបានរារាំងមិនឲ្យបរិភោគឬផឹក លើកលែងតែក្នុងអំឡុងពេលការសម្រាករបស់ពួកគេ នៅពេលដែលពួកគេអាចដោះម៉ាស់របស់ខ្លួន និងរក្សាគំលាតរាងកាយពីអ្នកដទៃបានដោយសុវត្ថិភាព។ នៅគ្រប់ពេលវេលាទាំងអស់នៅពេលបរិភោគឬផឹក បុគ្គលិកត្រូវតែរក្សាគំលាត យ៉ាងតិច 6 ហ្វីតពីអ្នកដទៃ។ នៅពេលបរិភោគឬផឹក គួរតែធ្វើនៅខាងក្រៅអគារ និងឆ្ងាយពីអ្នកដទៃ បើសិនជាអាចធ្វើបាន។ ការបរិភោគឬការផឹកនៅបន្ទប់តូចឬស្ថានីយការងារគឺប្រសើរជាងការបរិភោគនៅក្នុងបន្ទប់សម្រាក បើសិនជាការបរិភោគនៅបន្ទប់តូចឬស្ថានីយការងារផ្តល់ជូនគំលាតកាន់តែធំនិងរបាំងរវាងបុគ្គលិក។
- ❑ ចំនួនមនុស្សត្រូវបានកាត់បន្ថយហើយគំលាតរវាងបុគ្គលិកត្រូវបានបង្កើនជាអតិបរមានៅក្នុងបន្ទប់ ឬកន្លែងនានាដែលបុគ្គលិកប្រើសម្រាប់បរិភោគអាហារនិង/ឬសម្រាក។ ចំណុចនេះត្រូវបានសម្រេចដោយ៖
    - ○ កំណត់ចំនួនមនុស្សអតិបរមាដែលអនុញ្ញាតឲ្យមានការរក្សាគំលាតយ៉ាងតិចប្រាំមួយហ្វីតរវាងបុគ្គលនៅក្នុងបន្ទប់ ឬកន្លែងដែលប្រើសម្រាប់ការសម្រាក
    - ○ ឆ្លាស់ម៉ោងសម្រាក ឬម៉ោងបរិភោគអាហារ ដើម្បីកាត់បន្ថយចំនួនមនុស្សនៅក្នុងបន្ទប់ ឬទីកន្លែងដែលប្រើសម្រាប់ការបរិភោគអាហារនិងសម្រាក ព្រមទាំង
    - ○ ដាក់តុឃ្លាតពីគ្នាប្រាំមួយហ្វីត និងធានាបាននូវគំលាតប្រាំមួយហ្វីតរវាងកន្លែងអង្គុយ ដោយដកកៅអី ឬបិទបង់ស្អិតលើកៅអីដើម្បីកាត់បន្ថយចំនួនមនុស្ស ដាក់គ្រឿងសម្គាល់លើកម្រាលឥដ្ឋដើម្បីធានាបាននូវការរក្សាគំលាត និងរៀបចំកន្លែងអង្គុយតាមរបៀបដែលអាចកាត់បន្ថយការប៉ះពាល់ទល់មុខគ្នា។ ការប្រើប្រាស់របាំងខណ្ឌចែក ត្រូវបានលើកទឹកចិត្តដើម្បីទប់ស្កាត់ការរីករាលដាលបន្ថែមទៀត ប៉ុន្តែមិនគួរចាត់ទុកថាជាវិធីជំនួសឲ្យការកាត់បន្ថយចំនួនមនុស្ស និងការរក្សាគំលាតរាងកាយឡើយ។
- ❑ បុគ្គលិកត្រូវបានណែនាំឲ្យបោកគក់ ឬផ្លាស់ប្តូររបាំងមុខរបស់ខ្លួនជារៀងរាល់ថ្ងៃ។
- ❑ បុគ្គលិកក៏ទទួលបានស្រោមដៃសម្រាប់កិច្ចការដែលតម្រូវឲ្យពួកគេចាត់ចែងផ្ទៃដែលបានប៉ះពាល់ជាញឹកញាប់ ឬសម្រាប់ប្រើប្រាស់ក្នុងអំឡុងពេលពិនិត្យរករោគសញ្ញា។
- ❑ បុគ្គលិកត្រូវបានណែនាំឲ្យរក្សាគំលាតយ៉ាងតិចប្រាំមួយ (6) ហ្វីតពីភ្ញៀវនិងពីបុគ្គលិកដូចគ្នានៅគ្រប់កន្លែងទាំងអស់នៃកន្លែងបោះតង់នៅពេលថ្ងៃ។ បុគ្គលិកអាចមកជិតជាបណ្តោះអាសន្នតាមការចាំបាច់ដើម្បីជួយកុមារ ឬទៅតាមការចាំបាច់។
- ❑ បន្ទប់ទឹកនិងទីកន្លែងទូទៅផ្សេងទៀត ត្រូវបានសម្លាប់មេរោគជាញឹកញាប់ទៅតាមកាលវិភាគដូចខាងក្រោម៖
    - ○ បន្ទប់ទឹក ______________________________
    - ○ ផ្សេងទៀត ______________________________
- ❑ សារធាតុសម្លាប់មេរោគ និងការផ្គត់ផ្គង់ដែលពាក់ព័ន្ធគឺមានសម្រាប់បុគ្គលិកនៅទីតាំងដូចខាងក្រោម៖

  ______________________________
- ❑ ទឹកអនាម័យលាងដៃដែលមានប្រសិទ្ធភាពប្រឆាំងជំងឺ COVID-19 គឺមានសម្រាប់បុគ្គលិកទាំងអស់នៅទីតាំងដូចខាងក្រោម៖

  ______________________________
- ❑ បុគ្គលិកត្រូវបានរំលឹកឲ្យលាងដៃរបស់ខ្លួនឲ្យបានញឹកញាប់។
- ❑ ច្បាប់ចម្លងនៃពិធីការនេះត្រូវបានចែកចាយទៅបុគ្គលិកនីមួយៗ។
- ❑ ឲ្យច្រើនបំផុតតាមដែលអាចធ្វើបាន បុគ្គលិកនីមួយៗត្រូវបានកំណត់ឧបករណ៍ផ្ទាល់ខ្លួន និងត្រូវបានណែនាំឲ្យជៀសវាងការប្រើរួមគ្នាដូចជាទូរស័ព្ទ ថេប្លិត វិទ្យុពីរផ្លូវ គ្រឿងផ្គត់ផ្គង់ការងារផ្សេងទៀត ឬឧបករណ៍ការិយាល័យ នៅគ្រប់ពេលដែលអាចធ្វើបាន។ ពួកគេក៏ត្រូវបានណែនាំមិនឲ្យចែករំលែក PPE ជាដាច់ខាតផងដែរ។

- ❑ នៅពេលដែលត្រូវតែប្រើវត្ថុរួមគ្នា វត្ថុទាំងនោះត្រូវបានសម្លាប់មេរោគដោយប្រើផលិតផលសម្អាតដែលសមស្របសម្រាប់ផ្ទៃរវាងវេនធ្វើការ ឬការប្រើប្រាស់ម្តងៗ មួយណាដែលញឹកញាប់ជាង ដោយរាប់បញ្ចូលវត្ថុដូចខាងក្រោម៖ ម៉ាស៊ីនថតចម្លង ម៉ាស៊ីនទូរសារ ម៉ាស៊ីនបោះពុម្ព ទូរស័ព្ទ ក្តារចុច ប្រដាប់កិប ប្រដាប់ដោះគ្រាប់កិប ប្រដាប់បើកសំបុត្រ ផ្ទៃធ្វើការនៅកន្លែងទទួលភ្ញៀវ ស្ថានីយការងាររួមគ្នា ឧបករណ៍សំឡេងនិងវីដេអូ អាយកូម ។ល។
- ❑ ពេលវេលាត្រូវបានផ្តល់ឲ្យបុគ្គលិកដើម្បីអនុវត្តការសម្អាតក្នុងអំឡុងវេនធ្វើការរបស់ខ្លួន។ កិច្ចការសម្អាតត្រូវបានកំណត់ក្នុងអំឡុងម៉ោងធ្វើការ ជាផ្នែកមួយនៃភារកិច្ចការងាររបស់បុគ្គលិក។  បើចាំបាច់ កែប្រែម៉ោងដើម្បីធានាបាននូវការសម្អាតជាប្រចាំ និងហ្មត់ចត់ តាមការគួរ។ ជម្រើសសម្រាប់ក្រុមហ៊ុនសម្អាតរបស់ភាគីទីបីដើម្បីជួបតាមតម្រូវការសម្អាតកើនឡើង ត្រូវបានផ្តល់ឲ្យ តាមការចាំបាច់។
- ❑ ត្រួតពិនិត្យមើលអវត្តមានរបស់បុគ្គលិក និងមានក្រុមបុគ្គលិកបម្រុងដែលបានទទួលការបណ្តុះបណ្តាល។
- ❑ ពិចារណាដំឡើងម៉ាស៊ីនសម្អាតខ្យល់មានប្រសិទ្ធភាពខ្ពស់ចល័តសម្រាប់ការិយាល័យ និងកន្លែងធ្វើការផ្សេងទៀត ធ្វើឲ្យប្រសើឡើងនូវតម្រងខ្យល់របស់អគារឲ្យមានប្រសិទ្ធភាពខ្ពស់បំផុតតាមដែលអាចធ្វើបាន និងធ្វើការកែប្រែផ្សេងទៀតដើម្បីបង្កើនបរិមាណខ្យល់ខាងក្រៅ និងខ្យល់ចេញចូលនៅក្នុងការិយាល័យ និងទីកន្លែងផ្សេងៗទៀត។
- ❑ កែសម្រួលតម្រូវការប្រជុំបុគ្គលិកផ្សេងៗដើម្បីធានាបាននូវការរក្សាគំលាតរាងកាយ និងប្រើប្រាស់ការប្រជុំបុគ្គលឲ្យតិចជាងមុនដើម្បីគោរពតាមគោលការណ៍ណែនាំនៃការរក្សាគំលាតរាងកាយ។
- ❑ ធ្វើការប្រជុំជាមួយបុគ្គលិកតាមទូរស័ព្ទ តាមវិបិណា (webinar) ឬនៅខាងក្រៅអគារ នៅគ្រប់ពេលដែលអាចធ្វើបាន។ ពិចារណាការសម្ភាសន៍ និងការបញ្ចូលបុគ្គលិកថ្មីបែបនិម្មិត នៅពេលដែលអាចធ្វើបាន។
- ❑ គោលការណ៍ទាំងអស់ដែលបានពិពណ៌នានៅក្នុងបញ្ជីត្រួតពិនិត្យនេះ ក្រៅពីគោលការណ៍ដែលទាក់ទងនឹងល័ក្ខខ័ណ្ឌការងារ ត្រូវបានអនុវត្តទៅលើបុគ្គលិកដឹកជញ្ជូន និងក្រុមហ៊ុនផ្សេងៗទៀតដែលអាចស្ថិតនៅទីតាំងនោះក្នុងនាមជាភាគីទីបី។
- ❑ ស្រេចចិត្ត—ពិពណ៌នាពីវិធានការណ៍ផ្សេងទៀត៖

______________________________________________________________

## B. វិធានការណ៍ដើម្បីធានាបាននូវការរក្សាគំលាតរាងកាយ

- ❑ អនុវត្តវិធានការណ៍ដើម្បីធានាបាននូវការរក្សាគំលាតរាងកាយយ៉ាងតិចប្រាំមួយហ្វិតរវាង និងក្នុងចំណោមបុគ្គលិកនិងភ្ញៀវ។ នេះអាចរាប់បញ្ចូលការដំឡើងរនាំងកញ្ចក់ Plexiglass រវាងបុគ្គលិកនិងភ្ញៀវនៅក្នុងហាង បន្ទប់រង់ចាំ កន្លែងទទួលភ្ញៀវ ឬមជ្ឈមណ្ឌលភ្ញៀវ ឬការប្រើប្រាស់តម្រុយរូបភាពដើម្បីណែនាំភ្ញៀវពីកន្លែងដែលត្រូវឈរ ឬតម្រង់ជួរ។ ភ្ញៀវក៏គួរត្រូវបានណែនាំពីកន្លែងដែលត្រូវឈរ ដោយប្រើតម្រុយរូបភាព និង/ឬដោយប្រាប់ផ្ទាល់មាត់តាមការគួរ នៅពេលរង់ចាំប្រើប្រាស់ស្ថានីយយកទឹក ស្ថានីយបោះចោលសម្រាម RV ស្ថានីយបំពេញហ្គាស់ប្រូប៉ាន និងទីតាំងសេវាកម្មស្រដៀងគ្នាផ្សេងទៀត។
- ❑ បុគ្គលិកត្រូវបានរំលឹកឲ្យចៀសវាងការចាប់ដៃ ការទល់កណ្តាប់ដៃ ឬការទល់កែងដៃ និងការប៉ះពាល់ដោយផ្ទាល់ផ្សេងទៀត។
- ❑ ប្រតិបត្តិការគួរត្រួតពិនិត្យកន្លែងមនុស្សទំនងនឹងប្រមូលផ្តុំ និងធានាថាការរក្សាគំលាតរាងកាយ និងគោលការណ៍ណែនាំផ្សេងទៀតត្រូវបានអនុវត្តតាម។ ទីកន្លែងទាំងនេះអាចរាប់បញ្ចូលកន្លែងហែលទឹក ទីលានលេងកីឡា ច្រកផ្លូវលំ ទីកន្លែងប្រើប្រាស់ពេលថ្ងៃដែលពេញនិយម និងទីកន្លែងពិកនិក។ បិទស្លាកសញ្ញាអំពីសេចក្តីតម្រូវនៃការរក្សាគំលាតរាងកាយ។
- ❑ ទីកន្លែងខាងក្រោមនៅតែបន្តបិទ៖ ទីលានកីឡាបាល់បោះ និងកីឡាបាល់ទះ រចនាសម្ព័ន្ធយោងឡើងនិងសួនកម្សាន្ត។
- ❑ សម្រាប់ទីកន្លែងដែលផ្តល់សកម្មភាពខាងក្រៅបង់ថ្លៃ និងមានការគ្រប់គ្រង ចូរពិចារណាអនុវត្តប្រព័ន្ធកក់ទុកជាមុនដើម្បីដាក់កម្រិតចំនួនភ្ញៀវនៅទីកន្លែង។
- ❑ ចូរពិចារណាអនុវត្តជម្រើសចុះឈ្មោះចូលពីចម្ងាយសម្រាប់អ្នកមកដល់ថ្មីនៅកន្លែងបោះជំរុំ ឬឧទ្យាន RV នៅគ្រប់ពេលដែលអាចធ្វើបាន។ បិទស្លាកសញ្ញានៅច្រកចូលឧទ្យានដើម្បីជូនដំណឹងដល់ភ្ញៀវអំពីអ្វីដែលពួកគេត្រូវធ្វើនៅពេលមកដល់។ ឧទាហរណ៍ ដាក់លេខទូរស័ព្ទសម្រាប់ឲ្យភ្ញៀវទាក់ទងជាជាងការចូលក្នុងកន្លែងចុះឈ្មោះ។ លើកទឹកចិត្តការប្រើប្រាស់ការបង់ប្រាក់តាមអនឡាញ ស្ថានីយបង់ប្រាក់នៅនឹងកន្លែង ការបង់ប្រាក់តាមកាតឥណទាន ឬការបង់ប្រាក់តាមទូរស័ព្ទ នៅពេលដែលអាចធ្វើបាន។
- ❑ បើសិនជាមិនអាចធ្វើការចុះឈ្មោះចូលពីចម្ងាយបាន ចូរចុះឈ្មោះភ្ញៀវចូលនៅខាងក្រៅ និងផ្ញើបង្កាន់ដៃតាមអ៊ីម៉ែល។ នៅពេលដែលចាំបាច់ ចូរជូនឬនាំភ្ញៀវទៅកាន់ទីកន្លែងរបស់ពួកគេដោយផ្ទាល់បន្ទាប់ពីមកដល់ ដោយអនុវត្តតាមសេចក្តីតម្រូវនៃការរក្សាគំលាតរាងកាយ។ មានតែគ្រួសារតែមួយប៉ុណ្ណោះ ដែលគួរកាន់កាប់កន្លែងបោះជំរុំ ឬបន្ទប់សម្រាប់ជួលមួយ ហើយមិនគួរអនុញ្ញាតឲ្យភ្ញៀវដែលមិនបានចុះឈ្មោះចូលកន្លែងបោះជំរុំ ឬឧទ្យាន RV ឡើយ។

- ❑ គួរពិចារណាអនុវត្តដំណើរការសម្រាប់ឲ្យភ្ញៀវទិញទំនិញជាមុនពីហាងទូទៅ ដូចជាអុស ម្ហូបអាហារ ឬទំនិញផ្សេងៗទៀត និងឲ្យបុគ្គលិកបញ្ជូនទំនិញទាំងនោះទៅកាន់កន្លែងបោះជំរុំ ឬ RV របស់ភ្ញៀវ។
- ❑ ទីធ្លាខាងក្រៅដែលប្រើសម្រាប់ការប្រមូលផ្តុំ និងមុខងារជាក្រុម ដូចជាពន្លា កន្លែងបង្កាត់ភ្លើងរួមគ្នា ចង្ក្រាននៅជំរុំ សម្រាប់ប្រើជាសាធារណៈ និងវង្គមណ្ឌលគួរតែបន្តបិទ។ យកចេញ បំបែក ដាក់ស្លាកសញ្ញាបិទ ឬហ៊ុមព័ទ្ធបិទបង់អង្គុយ តុពិកនិកនៅទីកន្លែងទូទៅ និងកន្លែងអង្គុយសម្រាប់មនុស្សច្រើនទាំងអស់ (រាប់បញ្ចូលទាំងកន្លែងអង្គុយនៅជុំវិញកន្លែងដុតភ្លើង) ដើម្បីរារាំងភ្ញៀវកុំឲ្យប្រមូលផ្តុំ។
- ❑ ត្រូវតែរំសាយ ឬផ្អាកព្រឹត្តិការណ៍សាធារណៈ និង/ឬការជួបជុំប្រមូលផ្តុំទាំងអស់ ដោយរាប់បញ្ចូលទាំងភ្នក់ភ្លើង កន្លែងបោះជំរុំជាក្រុម ការបង្ហាញនៅវង្គមណ្ឌលនៅខាងក្រៅ ការសម្តែងតន្ត្រីឬការសម្តែងផ្សេងទៀត ឬព្រឹត្តិការណ៍ផ្សេងៗទៀត។
- ❑ ទីកន្លែងសម្រាប់ធ្វើពិចនិកតូចៗ ដូចជាកន្លែងដែលជាទូទៅប្រើប្រាស់សម្រាប់តែក្រុមគ្រួសារ អាចបន្តបើកដំណើរការបានដោយមានបិទផ្សាយការរឹតបន្តឹងដែលទាក់ទងនឹងការរក្សាគំលាតរាងកាយ (ឧ. ដាក់កម្រិតការប្រើប្រាស់សម្រាប់តែគ្រួសារមួយក្នុងពេលម្តង)។
- ❑ វាយតម្លៃកន្លែងបោះជំរុំ និងឧទ្យាន RV ដើម្បីកំណត់ថាតើឧទ្យានចាំបាច់ត្រូវប្រតិបត្តិការដោយបន្ថយចំនួនមនុស្សដើម្បីរក្សាគំលាតរាងកាយឬទេ។

## សកម្មភាពនៅខាងក្រៅ

- ❑ ប្រតិបត្តិករគួរចាត់វិធានការណ៍ដើម្បីប្រាកដថាសកម្មភាពដែលមានហានិភ័យ (risk) ខ្ពស់ ដូចជាសកម្មភាពដែលមិនត្រូវបានណែនាំដោយគោលការណ៍ណែនាំរបស់រដ្ឋ មិនកើតឡើងនៅលើកន្លែងរបស់ខ្លួន។
- ❑ វាយតម្លៃដំណើរការសម្រាប់ការជួល និងការឲ្យខ្ចីឧបករណ៍លំហែ និងកំណត់ថាតើមានបុគ្គលិកគ្រប់គ្រាន់ និងមានប្រដាប់ប្រដារសម្អាត និងសម្លាប់មេរោគដើម្បីបើកប្រតិបត្តិការបែបនោះឡើងវិញឬទេ។ សូមមើលការណែនាំរបស់ខោនធីនៅ ឧបករណ៍ខាងក្រៅសម្រាប់ជួល (outdoor equipment rentals) សម្រាប់ព័ត៌មានបន្ថែម។
- ❑ កែប្រែសកម្មភាពលំហែខាងក្រៅ នៅពេលចាំបាច់ ដើម្បីធានាថាអាចអនុវត្តពិធីការសម្អាត និងសម្លាប់មេរោគសមស្រប។
- ❑ អនុវត្តតាមគោលការណ៍ណែនាំនៅលើគេហទំព័រខោនធីសម្រាប់សកម្មភាពនៅខាងក្រៅផ្សេងៗ ដូចជាការបាញ់ធ្នូ កីឡាវាយកូនបាល់ ផ្លូវលំ ។ល។ ដើម្បីប្រាកដថាគេកំពុងអនុវត្តតាមពិធីការគ្រប់គ្រងការឆ្លងជំងឺ និងការរក្សាគំលាតរាងកាយបានគ្រប់គ្រាន់។ http://www.ph.lacounty.gov/media/Coronavirus/
- ❑ ការសម្អាត និងការសម្លាប់មេរោគ "ទំនិញទន់" ដូចជាអាវការពារជីវិត ឈុតសើម ខ្សែពួរ កាបូប ឬសាក់កាដូ អាចមានការលំបាកខ្លះៗ។ ឧបករណ៍បែបនោះត្រូវការការសម្អាតដែលមានប្រសិទ្ធភាព ឬ ឧបករណ៍សារពើភ័ណ្ឌគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឲ្យមាន "ពេលវេលាមិនប្រើ" (down time) គ្រប់គ្រាន់យ៉ាងតិចបីថ្ងៃបន្ទាប់ពីការប្រើប្រាស់ម្តងៗដើម្បីកាត់បន្ថយហានិភ័យ (risk) នៃការចម្លងជំងឺ COVID-19។
- ❑ កម្មវិធីប៉ះពាល់ខ្លាំង និងកីឡាដែលតម្រូវឲ្យមានការប៉ះពាល់ជិតស្និទ្ធក្នុងគំលាតតិចជាងប្រាំមួយហ្វីតរវាងសមាជិកមកពីគ្រួសារផ្សេងគ្នា គួរត្រូវបានផ្អាក។ នេះរាប់បញ្ចូលទាំងសកម្មភាពដូចជាព្រឹត្តិការណ៍កីឡាជាក្រុម កីឡាបាល់បោះ សកម្មភាពកីឡាកម្សាន្តការប្រណាំង ឬការរាំ។
- ❑ ដាក់កម្រិតលើសកម្មភាពលំហែនៅខាងក្រៅដែលមានការប៉ះពាល់ច្រើន ឬជិតស្និទ្ធសម្រាប់ក្រុមគ្រួសារ។ នេះរាប់បញ្ចូលទាំងការជួលទូក កន្លែងខ្សែពួរ និងឡើងជញ្ជាំង។ នៅកន្លែងបោះជំរុំ និងឧទ្យាន RV ចូរពិចារណាថាតើការដើរមើលធម្មជាតិរាត្រីមើលភាពយន្ត កីឡាវាយកូនហ្គោលខ្នាតតូច ការហ្វឹកហាត់ពីភូមិសាស្រ្ត ការប្រមាញ់ដោយខ្លួនឯង ឬសកម្មភាពផ្សេងៗទៀតអាចត្រូវបានបង្កើតឡើងសម្រាប់ក្រុមគ្រួសារ តាមរបៀបមួយដែលនៅតែរក្សាគំលាតរាងកាយ។
- ❑ នៅពេលឲ្យមនុស្សពាក់មួកការពារ ឧបករណ៍ សំលៀកបំពាក់ការពារ អាវការពារជីវិត ឬរបស់ផ្សេងទៀត បុគ្គលិកគួររក្សាគំលាតរាងកាយ។ នៅពេលអាចធ្វើបាន បុគ្គលិកគួរបង្ហាញរបៀបពាក់ និងដោះឧបករណ៍យ៉ាងត្រឹមត្រូវ ជាជាងការល្មើសគំលាតរាងកាយដើម្បីជួយ។

## បន្ទប់ទឹក និងទីកន្លែងងូតទឹករួម

- ❑ បន្ទប់ទឹកសាធារណៈ គួរត្រូវបានសម្អាត និងសម្លាប់មេរោគពេញមួយថ្ងៃ។ ចំណុះអតិបរមាសម្រាប់កន្លែងបោះជំរុំ ឧទ្យាន RV ឬទីកន្លែងលំហែគួរផ្អែកលើចំនួនបន្ទប់ទឹកដែលដំណើរការពេញលេញ ដែលប្រតិបត្តិករឧទ្យានអាចរក្សាបាន និងដែលអាចគាំទ្រដល់សេចក្តីបង្គាប់ឲ្យរក្សាគំលាតរាងកាយ។
- ❑ បន្ទប់ទឹករួម គួរត្រូវបានសម្អាតជាប្រចាំដោយប្រើសារធាតុសម្លាប់មេរោគដែលបានចុះបញ្ជីជាមួយ EPA ពេញមួយថ្ងៃ។

ផ្ទៃដែលប៉ះពាល់ច្រើនដូចជាក្បាលរ៉ូប៊ីណេ បង្គន់ ដៃទ្វារ និងកុងតាក់ភ្លើងគួរត្រូវបានសម្អាត និងសម្លាប់មេរោគឲ្យបានញឹកញាប់។ បុគ្គលិកគួរត្រូវបានបណ្តុះបណ្តាលអំពីគ្រោះថ្នាក់ និងការប្រើប្រាស់សមស្របនៃផលិតផលថ្មីតាមសេចក្តីតម្រូវ Ca/OSHA និងទទួលបានឧបករណ៍ការពារដែលចាំបាច់ផ្សេងៗ សម្រាប់ផលិតផលសម្អាតជាក់លាក់ ដូចជាការការពារភ្នែកឬស្រោមដៃ។

- ❑ បង្កើតនិងបិទផ្សាយកាលវិភាគសម្អាតនៅក្នុងបន្ទប់ទឹកដែលបើកទាំងអស់។ បិទផ្សាយកាលវិភាគសម្អាតនៅខាងមុខទ្វារដើម្បីឲ្យភ្ញៀវដឹងពីពេលដែលពួកគេអាច/មិនអាចប្រើបន្ទប់ទឹកបាន។ សូមប្រាកដថាបិទបន្ទប់ទឹកក្នុងអំឡុងដំណើរការសម្អាត និងសម្លាប់មេរោគ។
- ❑ គួរពិចារណាប្រើប្រាស់បញ្ជីត្រួតពិនិត្យ ឬប្រព័ន្ធសវនកម្មដើម្បីតាមដានថាតើការសម្អាតត្រូវបានធ្វើឡើងញឹកញាប់ប៉ុណ្ណា។
- ❑ អនុញ្ញាតឲ្យប្រើបន្ទប់ងូតទឹក លុះត្រាតែមានការខណ្ឌ ឬបិទស្លាកសញ្ញាដើម្បីបញ្ជាក់ពីសេចក្តីបង្គាប់ឲ្យរក្សាគំលាតរាងកាយប៉ុណ្ណោះ។ បើសិនជាមិនអាចមានការខណ្ឌ ឬការរក្សាគំលាតសមស្រប ទីកន្លែងទាំងនេះគួរតែបិទបន្ត។
- ❑ សូមប្រាកដថាទីកន្លែងអនាម័យអាចធ្វើប្រតិបត្តិការបាន និងមានស្តុកគ្រប់ពេលវេលា។ ផ្តល់សាប៊ូ ក្រដាសជូត និងទឹកអនាម័យលាងដៃបន្ថែម នៅពេលចាំបាច់។ បើអាចធ្វើបាន ចូរដំឡើងឧបករណ៍ដែលមិនបាច់ប៉ះ ដូចជាក្បាលរ៉ូប៊ីណេសិនស័រចាប់ចលនា ឧបករណ៍បញ្ចេញសាប៊ូ ឧបករណ៍បញ្ចេញទឹកអនាម័យលាងដៃ និងឧបករណ៍បញ្ចេញក្រដាសជូត។
- ❑ ទ្វារទៅកាន់បន្ទប់ទឹកដែលមិនប្រកាន់ភេទគួរតែអាចបើក និងបិទដោយមិនបាច់ប៉ះដៃទ្វារ។ បើសិនជាទ្វារមិនអាចបើកដោយមិនប៉ះដៃកាន់ ឬឧបករណ៍បញ្ជាទ្វារដោយដៃ ចូរទុកឲ្យទ្វារបើកចំហ និង/ឬដាក់ធុងសម្រាមនៅជិតទ្វារដើម្បីធានាថាគេអាច បោះចោលក្រដាសជូតបានយ៉ាងងាយស្រួលនៅពេលបិទបើកទ្វារ។ ទីតាំង និងការកំណត់ទីកន្លែងដាក់ធុងសម្រាមមិនគួរធ្វើ ឲ្យរាំងស្ទះដល់ច្រកចេញ ការជម្លៀស ឧបករណ៍សង្គ្រោះបន្ទាន់ ឬការសម្របសម្រួលសមហេតុផលណាមួយដែលបានផ្តល់ក្រោមច្បាប់ស្តីពីជនពិការអាមេរិកាំង (Americans with Disabilities Act) ឡើយ។ សូមប្រាកដថាធុងសម្រាមត្រូវបានចាក់ចោលជាប្រចាំ។
- ❑ ភ្ញៀវមកកន្លែងបោះជំរុំ ឧឡាន RV និងភ្ញៀវលំហែខាងក្រៅ គួរត្រូវបានណែនាំថា កន្ទន់អាចជាប្រភពចម្លងមេរោគនិងគួរចៀសវាងការដាក់ច្រាសដុសធ្មេញនិងវត្ថុផ្សេងទៀតដោយផ្ទាល់នៅលើផ្ទៃរបស់វា។ កន្ត្រកក៏អាចត្រូវបានប្រើសម្រាប់វត្ថុផ្ទាល់ខ្លួនដើម្បីដាក់កម្រិតលើការប៉ះពាល់ ជាមួយផ្ទៃផ្សេងទៀតនៅក្នុងបន្ទប់ទឹក។
- ❑ បុគ្គលិកគ្រប់គ្រងកន្លែងបោះជំរុំ និងឧឡាន RV គួរលើកទឹកចិត្តឲ្យភ្ញៀវស្ថិតនៅក្នុងយានយន្តដែលមានបង្គន់ និងឧបករណ៍ងូតទឹកដើម្បីប្រើប្រាស់ប្រដាប់ប្រដារបស់ខ្លួនជាជាងប្រើរបស់រួមគ្នា បើសិនជាអាចធ្វើបាន។
- ❑ ផ្តល់ព័ត៌មានអំពីរបៀបលាងដៃឲ្យបានសមស្រប ដូចជាការដាក់ស្លាកសញ្ញានៅក្នុងបន្ទប់ទឹក។

## អាងហែលទឹក និងទីកន្លែងលេងទឹក

- ❑ បច្ចុប្បន្ននេះមានតែអាងហែលទឹកខាងក្រៅប៉ុណ្ណោះ ទើបត្រូវបានអនុញ្ញាតឲ្យបើកដំណើរការ លើកលែងតែវាអាចត្រូវបានប្រើសម្រាប់ការហែលជាជុំដែលមានការកំណត់ត្រឹមត្រូវ (អ្នកហែលម្នាក់ក្នុងមួយផ្លូវ)។
- ❑ សូណា បន្ទប់ស្ទីម និងអាងងូតទឹកក្តៅគួរបិទបន្ត។
- ❑ រក្សាកម្រិតសារធាតុសម្លាប់មេរោគដែលសមស្រប (1-10 ភាគក្នុងមួយលានដែលគ្មានជាតិក្លរីន ឬ 3-8 ppm bromine) និង pH (7.2-8)។
- ❑ ប្រឹក្សាជាមួយក្រុមហ៊ុន ឬវិស្វករដែលបានរៀបចំទីកន្លែងលេងទឹក ដើម្បីសម្រេចថាតើសារធាតុសម្លាប់មេរោគ មួយណាដែលត្រូវបានអនុម័តដោយ EPA គឺល្អបំផុតសម្រាប់ទីកន្លែងមានទឹកនេះ។ ធានាបាននូវការប្រើប្រាស់ និងការរក្សាទុកសារធាតុសម្លាប់មេរោគដែលសុវត្ថិភាព និងត្រឹមត្រូវ ដូចជាការរក្សាទុកផលិតផលឲ្យឆ្ងាយពីក្មេង។
- ❑ រៀបចំប្រព័ន្ធមួយដែលគ្រឿងសង្ហារិម និងឧបករណ៍ (ឧ. កៅអីកន្លែងកម្សាន្ត) ដែលចាំបាច់ត្រូវសម្អាតនិងសម្លាប់មេរោគត្រូវបានរក្សាទុកដាច់ដោយឡែកពីគ្រឿងសង្ហារិមដែលត្រូវបានសម្អាត និងសម្លាប់មេរោគរួច។ ដាក់ស្លាក ឧបករណ៍ផ្ទុកសម្រាប់ឧបករណ៍ប្រើរួច ដែលមិនទាន់សម្អាត និងសម្លាប់មេរោគ និងឧបករណ៍ផ្ទុកសម្រាប់ឧបករណ៍ដែលបានសម្អាត និងសម្លាប់មេរោគរួច។
- ❑ លើកទឹកចិត្តឲ្យភ្ញៀវយកនិងប្រើប្រាស់កន្សែងរបស់ខ្លួន។ បើសិនជាមានផ្តល់កន្សែង ចូរបោកគក់កន្សែង និងសំលៀកបំពាក់ដោយយោងតាមការណែនាំរបស់ក្រុមហ៊ុនផលិត។ ប្រើប្រាស់សីតុណ្ហភាពទឹកសមស្របដែលក្តៅអ៊ុនៗបំផុត និងសម្ងួតវាឲ្យស្ងួតទាំងស្រុង។ ចាត់ចែងកន្សែងដោយពាក់ស្រោមដៃដែលប្រើហើយ អាចបោះចោលបាន និងដោយមានការរំខានតិចតួច ឧ. កុំក្រវ៉ាត់។
- ❑ រារាំងមនុស្សកុំឲ្យប្រើរបស់រួមគ្នា ជាពិសេសរបស់ដែលពិបាកសម្អាត និងសម្លាប់មេរោគ ឬផលិតផល ដែលសម្រាប់ប្រើដោយប៉ះជាមួយមុខ (ឧ. វ៉ែនតាហ្គូហ្គោល ដង្កៀបច្រមុះ និងបំពង់ខ្យល់)។

- ❑ សូមប្រាកដថា ទីកន្លែងមានឧបករណ៍គ្រប់គ្រាន់សម្រាប់អតិថិជន ដូចជាបន្ទះជំនួយហែលទឹក បំពង់រៀនហែលទឹក និងឧបករណ៍អណ្តែតផ្សេងទៀតដើម្បីកាត់បន្ថយការប្រើរួមគ្នានៅគ្រប់ពេលដែលអាចធ្វើបាន។ ដាក់កម្រិតការប្រើប្រាស់ឧបករណ៍មកត្រឹមអតិថិជនម្នាក់ក្នុងពេលម្តង និងធ្វើការសម្អាត និងសម្លាប់មេរោគវត្ថុបន្ទាប់ពីពេលប្រើម្តងៗ។
- ❑ ផ្លាស់ប្តូរប្លង់ជាន់ និងកន្លែងផ្សេងទៀតនៅជុំវិញអាងដើម្បីប្រាកដថាកន្លែងឈរ និងអង្គុយអាចគាំទ្រសេចក្តីបង្គាប់នៃការរក្សាគំលាតរាងកាយ។ នេះអាចរាប់បញ្ចូលការយកកៅអីកម្សាន្តចេញ ឬហ៊ុមព័ទ្ធបិទកន្លែងដើម្បីរារាំងការប្រើប្រាស់។
- ❑ ផ្តល់តម្រុយ ឬការណែនាំផ្ទាល់ (ឧ. ខ្សែផ្លូវនៅក្នុងទឹក ឬកៅអី និងតុនៅលើកន្លែងដើរជុំវិញអាង) និងតម្រុយអាចមើលឃើញ (ឧ. បង់ស្អិតនៅលើកន្លែងដើរជុំវិញ កម្រាលឥដ្ឋ ឬចិញ្ចើមផ្លូវ) និងស្លាកសញ្ញាដើម្បីប្រាកដថា បុគ្គលិក ភ្ញៀវ និងអ្នកហែលទឹកស្ថិតនៅគំលាតយ៉ាងតិចប្រាំមួយហ្វីតពីគ្នា ទាំងក្នុងនិងក្រៅអាងទឹក។
- ❑ នៅពេលដែលអាចធ្វើបាន ចូរដំឡើងរនាំងបាំងមិនជ្រាបទឹក ដូចជាកញ្ចក់ Plexiglas នៅកន្លែងដែលបុគ្គលិក និងអតិថិជនត្រូវតែប្រាស្រ័យទំនាក់ទំនង ហើយពិបាករក្សាគំលាតរាងកាយ។
- ❑ ពិចារណាអនុវត្តការកក់ទុកជាមុនសម្រាប់ការប្រើប្រាស់អាង ឬអនុវត្តយន្តការផ្សេងទៀតដើម្បីគាំទ្រការរក្សាគំលាតរាងកាយ។ នេះអាចរួមមានដូចជាការកក់ខ្សែផ្លូវទាំងមូលសម្រាប់ការហែលជាបុគ្គល។
- ❑ សូមប្រាកដថា ឆ្មាំងការពារដែលកំពុងធ្វើការការពារអាយុជីវិតយ៉ាងសកម្ម ក៏មិនត្រូវបានរំពឹងថាត្រូវត្រួតពិនិត្យ ការលាងដៃ ការប្រើប្រាស់ក្រណាត់បាំងមុខ ឬការរក្សាគំលាតរាងកាយនោះដែរ។ សូមប្រគល់ទំនួលខុសត្រូវនៃការត្រួតពិនិត្យនេះទៅឲ្យបុគ្គលិកម្នាក់ផ្សេងទៀត។
- ❑ ទីកន្លែងលេងទឹក គួរចៀសវាងសកម្មភាពដែលជំរុញឲ្យមានការប្រមូលផ្តុំជាក្រុម។

## កាប៊ីន និងកន្លែងជួល

- ❑ កន្លែងបោះជំរុំ និងឧទ្យាន RV ដែលមានកាប៊ីនឬកន្លែងជួលផ្សេងទៀត គួរចាត់វិធានការណ៍សមស្របដើម្បីសម្អាត និងសម្លាប់មេរោគកន្លែងទាំងនោះបន្ទាប់ពីប្រើប្រាស់រួចម្តងៗ។ នេះរាប់បញ្ចូលការជូតនិងសម្អាតរនាំងគ្រែ តុ តេឡេទូរទស្សន៍ សន្ទះក្បាលគ្រែ ផ្នែកខាងលើ ឧបករណ៍ផ្ទះបាយ ដៃទូទឹកកក ប្រដាប់បើកចង្ក្រាន កញ្ចក់ និងវត្ថុផ្សេងៗទៀត។
- ❑ ត្រូវតែដោះក្រណាត់ទាំងអស់ និងបោកគក់វាបន្ទាប់ពីភ្ញៀវនីមួយៗស្នាក់នៅ ដោយរាប់បញ្ចូលទាំងវត្ថុដែលមើលទៅដូចជាមិនទាន់បានប្រើ។ នៅពេលសម្អាតកម្រាលពូក កន្សែង ឬវត្ថុដែលបានបោកគក់ផ្សេងទៀតនៅក្នុងកន្លែងជួល ចូរប្រាកដថាបុគ្គលិកពាក់ស្រោមដៃដែលប្រើហើយអាចបោះចោលបាន នៅពេលចាត់ចែងឥវ៉ាន់បោកដែលកខ្វក់ រួចបោះស្រោមដៃនោះចោលបន្ទាប់ពីប្រើរួច។ លាងដៃជាមួយសាប៊ូ ឬប្រើទឹកអនាម័យលាងដៃភ្លាមៗបន្ទាប់ពីដោះស្រោមដៃ។ កុំរក្សាទុកក្រណាត់បន្ថែមនៅក្នុងកន្លែងជួល។ ផ្តល់វត្ថុបែបនោះទៅតាមសំណើតែប៉ុណ្ណោះ។
- ❑ កុំក្រវីឥវ៉ាន់បោកគក់ដែលកខ្វក់។ នេះនឹងកាត់បន្ថយភាពអាចទៅរួចនៃការបែកខ្ញែកមេរោគតាមរយៈខ្យល់។ បោកគក់វត្ថុតាមការសមស្រប ដោយយោងតាមការណែនាំរបស់ក្រុមហ៊ុនផលិត។ បើសិនជាអាចធ្វើបាន ចូរបោកគក់របស់របរដោយប្រើការកំណត់ទឹកក្តៅខ្ពស់បំផុតដែលសមស្របសម្រាប់វត្ថុ និងសម្ងួតវាឲ្យស្ងួតល្អ។ សម្អាត និងសម្លាប់មេរោគកន្ត្រក់បោកគក់តាមការណែនាំខាងលើសម្រាប់ផ្ទៃ។ បើអាចធ្វើបាន ចូរពិចារណាដាក់ថង់ខ្ចប់ដែលអាចបោះចោលបាន និងបោះចោលបន្ទាប់ពីប្រើរួច ឬអាចបោកគក់បានបន្ទាប់ពីប្រើរួច។
- ❑ វត្ថុក្នុងផ្ទះបាយ ដូចជាឆ្នាំង ខ្ទះ និងប្រដាប់ប្រដាបរិភោគ ត្រូវតែសម្អាតយ៉ាងល្អិតល្អន់ជាមួយសាប៊ូនិងទឹកក្តៅ យកល្អដាក់នៅក្នុងម៉ាស៊ីនលាងចាន បន្ទាប់ពីភ្ញៀវនីមួយៗស្នាក់នៅ។ ផ្តល់សាប៊ូលាងចាន និងអេប៉ុងថ្មីមិនទាន់ប្រើគ្រប់គ្រាន់សម្រាប់ភ្ញៀវនីមួយៗនៅពេលមកដល់។ ពិចារណាផ្លាស់ប្តូរប្រដាប់ប្រដាបរិភោគជាមួយឈុតប្រដាប់ប្រដាបរិភោគដែលប្រើតែម្តង បើសិនជាអាចធ្វើបាន។
- ❑ ពិចារណាចាប់ផ្តើមរយៈពេលរង់ចាំ 24 ម៉ោង បន្ទាប់ពីភ្ញៀវចុះឈ្មោះចេញ មុននឹងសម្អាតទីកន្លែងបោះជំរុំដែលផ្តល់កន្លែងស្នាក់នៅណាមួយ  ដោយរាប់បញ្ចូលទាំងកន្លែងជួលផងដែរ។
- ❑ កន្លែងជួលនានាដែលប្រើសម្រាប់ការប្រមូលផ្តុំធំៗ ដូចជាសន្និសីទ ឬការប្រជុំ មិនគួរបើកឡើយ រហូតដល់ប្រតិបត្តិការបែបនោះអាចបន្តបាន។

## ម្ហូបអាហារ និងការបរិភោគ

- ❑ អនុវត្តតាមការណែនាំរបស់នាយកដ្ឋានសុខភាពសាធារណៈ ទាក់ទងនឹងភោជនីយដ្ឋាន សម្រាប់ការណែនាំទាក់ទងនឹងម្ហូបអាហារ និង ការបរិភោគ។
- ❑ ប្រតិបត្តិករកន្លែងលំហែខាងក្រៅ មិនគួរប្រារព្ធកម្មវិធីបរិភោគអាហាររួមគ្នា ឬព្រឹត្តិការណ៍បរិភោគនិងផឹកបែបគ្រួសារស្រដៀងគ្នា ដែលបង្កើនហានិភ័យ (risk) នៃការឆ្លងមេរោគឡើយ។ បើសិនជាចាំបាច់ត្រូវបម្រើ ឬចែករំលែកម្ហូបអាហារនិងភេសជ្ជៈ

ចូរផ្តល់វត្ថុទាំងនោះនៅក្នុងឧបករណ៍ផ្ទុកសម្រាប់ការប្រើម្តង និងប្រើហើយអាចបោះចោលបាន នៅគ្រប់ពេលដែលអាចធ្វើបាន។ បុគ្គលិក ឬអ្នកស្ម័គ្រចិត្តដែលបម្រើម្ហូបអាហារ គួរលាងដៃឲ្យបានញឹកញាប់ និងពាក់ស្រោមដៃដែលអាចប្រើហើយអាចបោះចោលបាន និងរបាំងមុខ។

**ទីកន្លែងបោកគក់**

- ❑ បើចាំបាច់ ចូរកែសម្រួលម៉ោងប្រតិបត្តិការសម្រាប់បន្ទប់បោកគក់ ដើម្បីប្រាកដថាបុគ្គលិកមានពេលវេលាគ្រប់គ្រាន់ដើម្បីសម្អាត និងសម្លាប់មេរោគគម្របនិងទ្វារម៉ាស៊ីនបោក ប្រដាប់ការពារកម្តៅ ផ្នែកខាងលើតុនិងបញ្ជ កៅអីឬបង់អង្គុយ ឧបករណ៍បញ្ចេញសាប៊ូ ម៉ាស៊ីនលក់ទំនិញ ម៉ាស៊ីនប្តូរ កន្ទេន និងកន្លែងផ្សេងទៀតឲ្យបានញឹកញាប់។
- ❑ ពិចារណាដាក់ទឹកអនាម័យលាងដៃ និងក្រដាសជូតសម្លាប់មេរោគនៅក្នុងបន្ទប់បោកគក់ដើម្បីឲ្យភ្ញៀវអាចជូតកន្លែងមុន/ក្រោយពីពួកគេប្រើប្រាស់ម៉ាស៊ីន។
- ❑ យកហ្គេម សៀវភៅ ព្រឹត្តិប័ត្រព័ត៌មាន ឬរបស់ផ្សេងៗទៀតទាំងអស់ចេញពីទីកន្លែងបោកគក់។ យកកន្ត្រក ឬធុងបោកគក់ចេញ បើមានផ្តល់ជូន។
- ❑ ពិចារណាបង្កើតប្រព័ន្ធកក់ទីកន្លែងបោកគក់ ដើម្បីឲ្យបុគ្គលិកដឹងពីពេលវេលាដែលទីកន្លែងកំពុងត្រូវបានប្រើប្រាស់ ហើយភ្ញៀវអាចចៀសវាងការប្រាស្រ័យទាក់ទងដែលមិនចាំបាច់។ ចាក់សោទីកន្លែងបោកគក់នៅចន្លោះការកក់ដែលបានកំណត់ពេល ដើម្បីធានាបាននូវពេលវេលាគ្រប់គ្រាន់សម្រាប់សម្អាត។
- ❑ បើសិនជាមិនអាចប្រើប្រព័ន្ធកក់ ចូររក្សាគំលាតរាងកាយដោយបិទម៉ាស៊ីននៅចន្លោះនីមួយៗ ដូច្នេះភ្ញៀវអាចរក្សាគំលាតរាងកាយប្រាំមួយហ្វីតពីគ្នាបាន។
- ❑ លើកទឹកចិត្តឲ្យភ្ញៀវរង់ចាំនៅខាងក្រៅអគារ នៅពេលឥវ៉ាន់កំពុងត្រូវបានបោកគក់/សម្ងួត។ ម្យ៉ាងវិញទៀត ចូរប្រើប្រាស់តម្រុយរូបភាពដើម្បីណែនាំភ្ញៀវអំពីកន្លែងដែលត្រូវឈរ និងដាក់ម្រិតការចូលប្រើ ដូច្នេះភ្ញៀវអាចប្រើប្រាស់ម៉ាស៊ីនច្រើនដែលនៅជាមួយគ្នា។
- ❑ កំណត់ថាតើគួរមានចំនួនមនុស្សអតិបរមាប៉ុន្មាននាក់សម្រាប់ទំហំបន្ទប់ និងបិទស្លាកសញ្ញានៅលើទ្វារ ដែលបញ្ជាក់ថាអាចមានមនុស្សប៉ុន្មាននាក់នៅក្នុងបន្ទប់ក្នុងពេលម្តង អមដោយកាលវិភាគនៃការសម្អាត និងសម្លាប់មេរោគ។

## C. វិធានការណ៍ដើម្បីគ្រប់គ្រងការឆ្លងជំងឺ

- ❑ ទាក់ទងភ្ញៀវដែលមានការកក់ទុកជាមុននៅកន្លែងបោះជំរុំ និងឧទ្យាន RV មុនការមកដល់ដែលបានកំណត់របស់ពួកគេ ដើម្បីបញ្ជាក់ពីការកក់និងសាកសួរថាតើពួកគេ ឬនរណាម្នាក់នៅក្នុងគ្រួសាររបស់ពួកគេកំពុងចេញរោគសញ្ញាជំងឺ COVID-19 ណាមួយឬទេ។ បើសិនជាភ្ញៀវឆ្លើយថាមាន ចូរកំណត់ពេលឡើងវិញ ឬរំសាយការកក់។
- ❑ ភ្ញៀវដែលមកដល់អាជីវកម្មត្រូវបានរំលឹកឲ្យពាក់របាំងមុខនៅគ្រប់ពេលវេលា (លើកលែងពេលបរិភោគ ឬផឹក បើសិនជាអាចធ្វើបាន) ខណៈពេលនៅក្នុងអាជីវកម្ម ឬក្នុងទីធ្លារបស់អាជីវកម្ម។ នេះអនុវត្តទៅលើមនុស្សធំទាំងអស់និងកុមារដែលមានអាយុចាប់ពី 2 ឆ្នាំឡើងទៅ។ មានតែបុគ្គលដែលត្រូវបានណែនាំមិនឲ្យពាក់របាំងមុខដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្ររបស់ខ្លួនប៉ុណ្ណោះ ទើបត្រូវបានលើកលែងពីការពាក់ម៉ាសនេះ។ ដើម្បីគាំទ្រសុវត្ថិភាពរបស់បុគ្គលិកអ្នកនិងភ្ញៀវផ្សេងទៀត គួរផ្តល់របាំងមុខដល់ភ្ញៀវដែលមកដល់តែមិនមានម៉ាស។
- ❑ ការត្រួតពិនិត្យ ត្រូវបានធ្វើឡើងមុនពេលភ្ញៀវអាចចូលក្នុងទីកន្លែង។ ការពិនិត្យត្រូវតែរាប់បញ្ចូលការពិនិត្យពាក់ព័ន្ធនឹងការក្អក ការដកដង្ហើមខ្លី ការពិបាកដកដង្ហើម គ្រុនក្តៅឬគ្រុនរងា និងថាតើភ្ញៀវនោះកំពុងស្ថិតក្រោមសេចក្តីបង្គាប់ឲ្យនៅដាច់ដោយឡែកឬឲ្យនៅដាច់ពីគេនាពេលបច្ចុប្បន្នឬទេ។ ការត្រួតពិនិត្យទាំងនេះអាចធ្វើបានដោយផ្ទាល់ ឬតាមរយៈវិធីផ្សេងដូចជាប្រព័ន្ធចុះឈ្មោះតាមអនឡាញ ឬតាមរយៈស្លាកសញ្ញាដែលបានបិទនៅច្រកចូលទីកន្លែងដោយថ្លែងថាភ្ញៀវដែលមានរោគសញ្ញាទាំងនេះមិនគួរចូលក្នុងទីកន្លែងឡើយ។
- ❑ ធ្វើការសម្អាតយ៉ាងល្អិតល្អន់នៅតាមកន្លែងដែលមានមនុស្សចេញចូលច្រើន ដូចជាកន្លែងចុះឈ្មោះភ្ញៀវ និងបន្ទប់រង់ចាំមជ្ឈមណ្ឌលភ្ញៀវ បន្ទប់សម្រាករបស់បុគ្គលិក បន្ទប់ទឹក និងកន្លែងច្រកចេញចូល ដូចជាជណ្តើរនិងបង្កាន់ដៃពេញមួយថ្ងៃ។
- ❑ សម្លាប់មេរោគលើផ្ទៃ និងវត្ថុដែលបានប្រើទូទៅឲ្យបានញឹកញាប់ ដូចជាចង្កូតយានយន្តនិងចង្អឹះលេខ សោ ឧបករណ៍ក្បាលរ៉ូប៊ីណេទឹក ធុងសម្រាម កៅអីអង្គុយកម្សាន្ត ឧបករណ៍ប្រើប្រាស់រួមគ្នា ដៃទ្វារ ផ្ទៃធ្វើការ បង្កន់ និងទីកន្លែងលាងដៃ។
- ❑ ប្រតិបត្តិការកន្លែងលំហែខាងក្រៅគួរប្រឹក្សាជាមួយក្រុមហ៊ុនផលិតឧបករណ៍ ដើម្បីកំណត់ពីជំហានសម្លាប់មេរោគសមស្របជាពិសេសសម្រាប់ផ្ទៃដែលទន់ មានរន្ធ។ លើកទឹកចិត្តឲ្យភ្ញៀវយកនិងប្រើប្រាស់ឧបករណ៍របស់ខ្លួន នៅគ្រប់ពេលដែលអាចធ្វើបាន។

- ❑ បំពាក់កន្លែងទទួលភ្ញៀវ ទីកន្លែងចុះឈ្មោះចូល និងកន្លែងធ្វើការបុគ្គលិកជាមួយនឹងផលិតផលអនាម័យសមស្រប ដូចជាទឹកអនាម័យលាងដៃនិងក្រដាសជូតសម្លាប់មេរោគ។
- ❑ គ្រឿងកម្សាន្តដូចជាផែនទីផ្លូវលំ សៀវភៅ ទស្សនាវដ្តី កាហ្វេ ទឹក កន្លែងបម្រើដោយខ្លួនឯង (លុះត្រាតែមិនបាច់ប៉ះ) និងវត្ថុផ្សេងៗទៀតសម្រាប់ភ្ញៀវ ត្រូវតែយកចេញពីកន្លែងទទួលភ្ញៀវដើម្បីជួយកាត់បន្ថយចំណុចប៉ះ និងការប្រាស្រ័យទាក់ទងរបស់ភ្ញៀវ។ ផែនទីផ្លូវលំ និងឯកសារព័ត៌មានដែលបានបោះពុម្ព អាចចែកជូនដល់ភ្ញៀវនៅពេលមកដល់សម្រាប់ការប្រើប្រាស់ជាបុគ្គលរបស់ពួកគេ។
- ❑ វត្ថុដែលបានប៉ះជាទូទៅ និងពិបាកសម្អាត ដូចជាក្តារហ្គេម ឬសៀវភៅប្រើរួមគ្នា មិនគួរឲ្យភ្ញៀវខ្ចីឡើយ បើសិនជាអាចធ្វើបាន។ បើសិនជាឲ្យភ្ញៀវខ្ចីវត្ថុបែបនោះ ចូរពិចារណាដាក់វត្ថុដែលបានប្រគល់ត្រឡប់មកវិញនៅក្នុងឧបករណ៍ផ្ទុករយៈពេលយ៉ាងតិចបំផុតបីថ្ងៃមុននឹងឲ្យភ្ញៀវផ្សេងទៀតខ្ចី។
- ❑ អនុវត្តតាមគោលការណ៍ណែនាំរបស់ CDC ដើម្បីធានាថាប្រព័ន្ធទឹកទាំងអស់គឺមានសុវត្ថិភាពសម្រាប់ប្រើប្រាស់ បន្ទាប់ពីទីកន្លែងបិទទ្វារក្នុងរយៈពេលយូរ ដើម្បីកាត់បន្ថយហានិភ័យនៃជំងឺ Legionnaires និងជំងឺផ្សេងទៀតដែលទាក់ទងនឹងទឹក។
- ❑ ជាញឹកញាប់បន្ទប់ទឹកដែលគ្មានទឹកហូរ ដូចជាបង្គន់ចល័ត និងបង្គន់គ្មានទឹក (vault toilet) មិនមានផ្ទុកផលិតផលអនាម័យសម្រាប់ដៃឡើយ។ សូមលើកទឹកចិត្តឲ្យភ្ញៀវរៀបចំយកទឹកអនាម័យលាងដៃរបស់ខ្លួនដែលមានជាតិអាល់កុលយ៉ាងតិច 60% សម្រាប់ប្រើប្រាស់នៅតាមទីកន្លែងទាំងនេះ។ បើបានផ្តល់ជូន ចូរប្រាកដថាទីកន្លែងលាងដៃចល័តត្រូវបានថែទាំនិងមានសាប៊ូ កន្សែង និងការផ្គត់ផ្គង់ទឹកគ្រប់គ្រាន់។
- ❑ សម្អាតបន្ទប់ទឹកទៅតាមកាលវិភាគញឹកញាប់ជាងមុន ដើម្បីរក្សាវាឲ្យស្អាតល្អ និងលើកទឹកចិត្តឲ្យអ្នកបោះតង់និងភ្ញៀវប្រើវាដោយចៀសវាងអ្នកបោះតង់មិនប្រើបន្ទប់ទឹកដែលកខ្វក់និងគ្មានអនាម័យ និងបែរទៅប្រើទីវាលខាងក្រៅទៅវិញ។ នៅពេលដែលអាចធ្វើបាន ចូរផ្តល់គម្របអង្គុយដែលប្រើហើយអាចបោះចោលបាននៅក្នុងបន្ទប់ទឹក។
- ❑ លើកទឹកចិត្តឲ្យភ្ញៀវយកអ្វីដែលពួកគេបានខ្ចប់មកត្រូវបានខ្ចប់យកទៅវិញ នៅគ្រប់ពេលដែលអាចធ្វើបាន ដើម្បីកាត់បន្ថយចំនួនសម្រាមដែលបុគ្គលិកត្រូវបោះចោលនៅកន្លែងបោះជំរុំ ឧទ្យាន ផ្លូវលំ ឬទីកន្លែងផ្សេងៗទៀត។
- ❑ ស្ថានីយយកទឹក ស្ថានីយបោះចោល RV និង ស្ថានីយបំពេញហ្គាស់ប្រូប៉ាន ត្រូវតែសម្អាតនិងសម្លាប់មេរោគជារៀងរាល់ថ្ងៃ ហើយបុគ្គលិកគួរតែជូតឧបករណ៍បន្ទាប់ពីប្រើម្តងៗ។ បើអាចធ្វើបាន ចូរដាក់ទឹកអនាម័យលាងដៃនៅជិតទីកន្លែងទាំងនេះសម្រាប់ឲ្យភ្ញៀវនិងបុគ្គលិកប្រើប្រាស់។
- ❑ បុគ្គលិកគួរចៀសវាងការប្រើប្រាស់ឧបករណ៍ ទូរស័ព្ទ គ្រឿងអេឡិចត្រូនិក និងគ្រឿងការិយាល័យរួមគ្នាឲ្យបានច្រើនបំផុតតាមដែលអាចធ្វើបាន និងនៅពេលអាចធ្វើបាន ចូរប្រាកដថាបុគ្គលិកមានកន្លែងធ្វើការដាច់ដោយឡែកសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន។ កុំប្រើ PPE រួមគ្នាជាដាច់ខាត។
- ❑ នៅពេលជ្រើសរើសសារធាតុគីមីសម្រាប់សម្អាត និយោជកគួរប្រើផលិតផលដែលបានអនុម័តឲ្យប្រើប្រាស់ប្រឆាំងនឹងជំងឺ COVID-19 នៅលើបញ្ជី N ដែលបានអនុម័តរបស់ភ្នាក់ងារការពារបរិស្ថាន (EPA) និងអនុវត្តតាមការណែនាំរបស់ផលិតផល។ ប្រើប្រាស់សារធាតុសម្លាប់មេរោគដែលបានសរសេរថាមានប្រសិទ្ធភាពប្រឆាំងនឹងភ្នាក់ងារមេរោគ សូលុយស្យុងធ្វើឲ្យស (Bleach) នៅតាមផ្ទះដែលបានពង្រាវ (5 ស្លាបព្រាក្នុងទឹកមួយហ្គាឡុង) ឬសូលុយស្យុងអាល់កុលដែលមានជាតិអាល់កុលយ៉ាងតិច 70% ដែលសមស្របសម្រាប់ផ្ទៃ។ ផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកអំពីការណែនាំរបស់ក្រុមហ៊ុនផលិត និងសេចក្តីតម្រូវ Cal/OSHA សម្រាប់ការប្រើប្រាស់ដែលមានសុវត្ថិភាព។ បុគ្គលិកដែលប្រើផលិតផលសម្អាត ឬសារធាតុសម្លាប់មេរោគ គួរតែពាក់ស្រោមដៃ និងឧបករណ៍ការពារផ្សេងទៀតដូចបានតម្រូវដោយផលិតផល។
- ❑ បន្ទាប់ពីភ្ញៀវនីមួយៗស្នាក់នៅ គ្រឿងកម្សាន្តនៅតាមកន្លែងនីមួយៗគួរត្រូវបានជូត សម្អាត និងសម្លាប់មេរោគយ៉ាងសមស្រប។ នេះរាប់បញ្ចូលដូចជាចង្ក្រាន BBQ កៅអី កន្លែងអង្គុយបន្ទាប់បន្សំទាំងអស់ (ឧ. ទោង ឬបង់អង្គុយ) ក្បាលរ៉ូប៊ីណេទឹក ខ្សែភ្លើង RV និងទុយោទឹក។
- ❑ សូមប្រាកដថា បុគ្គលិកទាំងអស់ត្រូវបានបណ្តុះបណ្តាលឲ្យប្រើប្រាស់ និងមានការផ្គត់ផ្គង់គ្រប់គ្រាន់នូវផលិតផលសម្អាត និងសម្លាប់មេរោគគ្រប់មុខងារ នៅពេលចាំបាច់។
- ❑ បុគ្គលិកសម្អាត ឬបុគ្គលិកថែទាំត្រូវតែដឹង បើសិនជាពួកគេទៅធ្វើការនៅទីតាំងដែលអ្នកជំងឺបានទៅទីនោះ។ ភាគីទីបីដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សេវាកម្មសម្អាតដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានណែនាំសម្រាប់ការសម្លាប់មេរោគនៅទីកន្លែងដែលបានប៉ះពាល់។
- ❑ បើសិនជាបុគ្គលិកសម្អាត ឬបុគ្គលិកថែទាំត្រូវបានស្នើឲ្យសម្លាប់មេរោគនៅកន្លែងដែលមានករណីជំងឺ COVID-19 ពួកគេមិនត្រូវបានចាប់ផ្តើមប្រតិបត្តិការឡើយ លុះត្រាតែប្រតិបត្តិករកន្លែងបោះជំរុំ ឬ RV បានផ្តល់ឧបករណ៍ការពារ និងការបណ្តុះបណ្តាលបានសមស្រប។ បុគ្គលិកសម្អាត ឬបុគ្គលិកថែទាំត្រូវតែពាក់ស្រោមដៃដែលប្រើហើយអាចបោះចោលបានសម្រាប់កិច្ចការទាំងអស់នៅក្នុងដំណើរការសម្អាត រាប់បញ្ចូលទាំង ការចាត់ចែងសម្រាម។ គេគួររំលឹកបុគ្គលិកឲ្យលាងដៃជាមួយសាប៊ូ

និងទឹកភ្លាមៗបន្ទាប់ពីដោះស្រោមដៃ ឬប្រើប្រាស់ទឹកអនាម័យលាងដៃ។ PPE បន្ថែមអាចត្រូវបានតម្រូវ ដែលរួមមានដូចជាវ៉ែនតាហ្គោហ្គោល ដោយផ្អែកលើផលិតផលសម្អាត/សម្លាប់មេរោគដែលកំពុងប្រើនិងថាតើមានហានិភ័យ (risk) នៃការខ្ទាតទឹកឬទេ។

- ❑ បុគ្គលិកសម្អាតត្រូវតែទទួលការបណ្តុះបណ្តាល និងព័ត៌មានអំពីគ្រោះថ្នាក់នៃផលិតផលសម្អាត និងសារធាតុសម្លាប់មេរោគដែលបានប្រើ អាចរកបាននូវសន្លឹកទិន្នន័យសុវត្ថិភាព PPE ដែលចាំបាច់ និងខ្យល់ចេញចូលដែលចាំបាច់។
- ❑ បុគ្គលិកគួរមានខ្យល់ចេញចូល (លំហូរខ្យល់) គ្រប់គ្រាន់នៅក្នុងទីកន្លែងដែលពួកគេកំពុងសម្អាត។ បើសិនជាសម្អាតនៅក្នុងបន្ទប់ទឹកឬកន្លែងតូចៗផ្សេងទៀត ចូរប្រាកដថាបានបើកទ្វារនិងបង្អួច។
- ❑ ដើម្បីកាត់បន្ថយហានិភ័យ (risk) នៃជំងឺហឺតដែលទាក់ទងនឹងការសម្លាប់មេរោគ កម្មវិធីគួរមានគោលបំណងជ្រើសរើសផលិតផលសម្លាប់មេរោគនៅលើបញ្ជី N ដែលមានធាតុផ្សំសុវត្ថិភាពសម្រាប់ជំងឺហឺត (អ៊ីដ្រូសែនពែរ៉ុកស៊ីត អាស៊ីតស៊ីទ្រិក ឬអាស៊ីតឡាក់ទិក)។ ចៀសវាងផលិតផលដែលលាយធាតុផ្សំទាំងនេះជាមួយអាស៊ីត peroxyacetic, sodium hypochloric (bleach) ឬធាតុអាម៉ូញាក់ (quaternary ammonium) ដែលអាចបណ្តាលឲ្យមានជំងឺហឺត។
- ❑ ត្រូវរំលឹកភ្ញៀវកន្លែងបោះជំរុំ និងឧទ្យាន RV ឲ្យរក្សាគំលាតប្រាំមួយហ្វីតពីបុគ្គលិកជួសជុល សម្អាត ឬថែទាំដែលស្ថិតនៅក្នុងក្រុមតំហែទាំ។ អនុវត្តដំណើរការដើម្បីចុះឈ្មោះចូលឲ្យឆាប់រហ័សជាមួយបុគ្គលិក ដើម្បីធានាថាភ្ញៀវកំពុងអនុវត្តតាមពិធីការនេះ។ សូមប្រាកដថាបុគ្គលិកអាចចែករំលែកព័ត៌មានទាំងនោះដោយមិនមានការភ័យខ្លាចពីការផ្តាច់ផ្តួល ឬសងសឹក។
- ❑ ប្រតិបត្តិករកន្លែងបោះជំរុំ និងឧទ្យាន RV គួរវាយតម្លៃថាតើឧទ្យានសត្វឆ្កែនៅលើទីកន្លែងគឺធំល្មមដើម្បីសម្រួលដល់ភ្ញៀវនិងសត្វរបស់ពួកគេខណៈដែលរក្សាគំលាតរាងកាយសមស្របឬទេ។ បើសិនជាទីធ្លាមិនគ្រប់គ្រាន់ ឧទ្យានសត្វឆ្កែ ត្រូវតែធ្វើការពង្រីក ដាក់កម្រិតចំនួន ឬបិទ។

## D. វិធានការណ៍ដែលទំនាក់ទំនងជាមួយសាធារណៈជន

- ❑ ប្រតិបត្តិករកន្លែងបោះជំរុំ និងឧទ្យាន RV គួរចាត់វិធានការណ៍ដើម្បីប្រាកដថាភ្ញៀវយល់ដឹងយ៉ាងច្បាស់ពីគោលការណ៍និងនីតិវិធីថ្មីរបស់ឧទ្យានមុនពេលពួកគេមកដល់។ គោលការណ៍បែបនេះ គួររាប់បញ្ចូលសិទ្ធិសម្រាប់ឲ្យប្រតិបត្តិករកន្លែងបោះជំរុំ និងឧទ្យាន RV រំសាយការកក់សម្រាប់ភាគីដែលមានភ្ញៀវចេញរោគសញ្ញា និង នីតិវិធីចុះឈ្មោះចូលថ្មី និងសេចក្តីបង្គាប់នៃការរក្សាគំលាតរាងកាយ និងកាលវិភាគសម្អាតនិងសម្លាប់មេរោគសម្រាប់ទីកន្លែងស្នាក់នៅ គ្រឿងកម្សាន្ត និងទីកន្លែងទូទៅដូចជាកន្លែងចុះឈ្មោះចូល/ចុះឈ្មោះ និងហាងទូទៅក្នុងឧទ្យានឬមជ្ឈមណ្ឌលភ្ញៀវ។
- ❑ ផ្តល់ព័ត៌មានដល់ភ្ញៀវអំពីប្រធានបទដូចខាងក្រោម៖
    - ○ ធ្វើផែនការជាមុន ធ្វើការកក់ទុកជាមុននិងទិញលិខិតអនុញ្ញាត អុស ទឹកកកនិងទំនិញផ្សេងទៀតតាមអនឡាញឬតាមទូរស័ព្ទមុនពេលមកដល់ទីកន្លែង។
    - ○ ត្រូវចេះគ្រប់គ្រងខ្លួនឯង និងមានវត្ថុគ្រប់គ្រាន់សម្រាប់ខ្លួនឯងតាមដែលអាចធ្វើបាន។ ឧទាហរណ៍ មកដល់ដោយមានត្រៀមរួចជាស្រេចជាមួយនឹងសាប៊ូ គ្រឿងសម្លាប់មេរោគលើផ្ទៃ ទឹកអនាម័យលាងដៃ កន្សែង កន្សែងដៃ និងក្រដាសបន្ទប់ទឹករបស់អ្នកផ្ទាល់។ ជាការល្អ ក៏គួរយកក្រដាសជូតសម្លាប់មេរោគដើម្បីសម្អាតមុននិងក្រោយប្រើទីកន្លែងទូទៅផងដែរ។ យកឧបករណ៍កីឡា កន្សែង គ្រឿងសង្គ្រោះបឋម និងវត្ថុផ្សេងៗទៀតរបស់អ្នកផ្ទាល់ ដែលចាំបាច់សម្រាប់ការលំហែនៅខាងក្រៅ នៅគ្រប់ពេលដែលអាចធ្វើបាន។ ភ្ញៀវគួរយកកម្រាលតុប្លាស្ទិកសម្រាប់តុពិចនិកដែលអាចបោះចោលបាន ឬយកទៅផ្ទះវិញសម្រាប់បោកគក់។
    - ○ ដើម្បីប្រាកដថាការរក្សាគំលាតរាងកាយត្រូវបានគោរពតាម ភ្ញៀវគួររៀបចំកន្លែងបោះជំរុំឬកន្លែងពិចនិករបស់ខ្លួនដើម្បីបង្កើនគំលាតពីកន្លែងបោះជំរុំ និងកន្លែងពិចនិកដែលនៅក្បែរ ដែលមានមនុស្សមកពីគ្រួសារផ្សេង។
    - ○ កម្មវិធីនិងទីកន្លែងជាច្រើនអាចត្រូវបានរំសាយឬបិទ ដូច្នេះភ្ញៀវគួរពិនិត្យមើលធនធានអនឡាញសម្រាប់ព័ត៌មានថ្មីៗអំពីការផ្លាស់ប្តូរច្បាប់ និងការបិទដើម្បីដឹងថាអ្វីគួរត្រូវរំពឹងនៅពេលមកដល់។
    - ○ សង្កេតមើលពិធីការនៃការសម្អាតទាំងអស់សម្រាប់ទីកន្លែងដែលបម្រើសេវាដោយខ្លួនឯង និងគ្រឿងកម្សាន្តមុននឹងប្រើប្រាស់វា។
    - ○ ទុកគ្រឿងសង្ហារឹម ដូចជាតុនិងកៅអីពិចនិកឲ្យដូចពីមុនវិញ ព្រោះបុគ្គលិកឧទ្យានអាចនឹងបានរៀបចំវត្ថុទាំងនេះបានសមស្របដើម្បីលើកកម្ពស់ការរក្សាគំលាតរាងកាយ។
    - ○ អនុវត្តតាមស្លាកសញ្ញាណែនាំ - ឧ. រង់ចាំវេនរបស់អ្នក និងគោរពតាមការកំណត់ចំនួនមនុស្ស - ដែលនឹងលើកកម្ពស់ការរក្សាគំលាតរាងកាយនៅក្នុងអគារ ការមើលពីលើ និងជុំវិញទីធ្លាបិទជិតផ្សេងទៀត។
    - ○ ធ្វើផែនការនៃការធ្វើដំណើររបស់អ្នកតាមវិធីដែលមានសុវត្ថិភាពនិងមានទំនួលខុសត្រូវ។ ចូរចងចាំថាតំបន់ជនបទ

និងប្រតិបត្តិការសង្គ្រោះតម្រូវឲ្យមានអ្នកឆ្លើយតបបន្ទាន់ច្រើន ហើយតម្រូវការបន្ថែមលើធនធាននៃការថែទាំសុខភាពទាំងនោះធ្វើឲ្យមនុស្សគ្រប់គ្នាមានហានិភ័យ (risk)។

- ❑ រក្សាប្រព័ន្ធទំនាក់ទំនងដែលអនុញ្ញាតឲ្យបុគ្គលិក និងភ្ញៀវរាយការណ៍ពីរោគសញ្ញាដោយខ្លួនឯង និងទទួលបានការជូនដំណឹងភ្លាមៗអំពីការប៉ះពាល់ ការបិទ ខណៈដែលរក្សាការសម្ងាត់។
- ❑ ច្បាប់ចម្លងនៃពិធីការនេះត្រូវបានបិទផ្សាយនៅគ្រប់ច្រកចូលសាធារណៈទាំងអស់មកក្នុងកន្លែងបោះជំរុំ។
- ❑ ស្លាកសញ្ញាត្រូវបានបិទផ្សាយដែលណែនាំភ្ញៀវថាពួកគេគួរតែស្ថិតនៅផ្ទះ បើសិនជាឈឺដោយមានរោគសញ្ញាផ្លូវដង្ហើម។
- ❑ ច្រកអនឡាញនៃអាជីវកម្ម (គេហទំព័រ បណ្តាញសង្គម ។ល។) ផ្តល់ព័ត៌មានច្បាស់លាស់អំពីពិធីការបច្ចុប្បន្ន ការតម្រូវឲ្យប្រើបាំងមុខ ការអនុវត្តការគ្រប់គ្រងការឆ្លងជំងឺ និងសេចក្តីតម្រូវនៃការរក្សាគំលាតរាងកាយ។

## E. វិធានការណ៍ដែលធានាបាននូវការប្រើប្រាស់សេវាកម្មសំខាន់ៗដោយស្មើភាព

- ❑ សេវាកម្មដែលចាំបាច់ខ្លាំងសម្រាប់ភ្ញៀវត្រូវបានផ្តល់អាទិភាព។
- ❑ វិធានការណ៍ត្រូវបានអនុវត្តដើម្បីធានាបាននូវសេវាកម្មសម្រាប់ភ្ញៀវដែលមានការលំបាកក្នុងការផ្លាស់ទី និង/ឬដែលមានហានិភ័យខ្ពស់នៅទីសាធារណៈ។

**វិធានការណ៍បន្ថែមទាំងឡាយដែលខុសពីខាងលើ គួរត្រូវបានរាយនៅលើទំព័រដាច់ដោយឡែក ដែលអាជីវកម្មគួរភ្ជាប់ជាមួយឯកសារនេះ។**

**អ្នកអាចទាក់ទងបុគ្គលខាងក្រោមជាមួយសំណួរ ឬមតិអំពីពិធីការនេះ៖**

**ឈ្មោះទំនាក់ទំនងអាជីវកម្ម៖** _______________

**លេខទូរស័ព្ទ៖** _______________

**កាលបរិច្ឆេទកែសម្រួលចុងក្រោយ៖** _______________